# វិន័យប្បករណ៍

**បង្រៀនដោយលោកគ្រូ អគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស**

**ថ្ងៃច័ន្ទ ១ រោច ខែទុតិយាសាឍ ឆ្នាំកុរ នព្វស័ក**

**ពុទ្ធសករាជ ២៥៥១**

ប្រមូលរួបរួមដោយ **ហាយ ចំរើន**

## ៚ តទនន្តរំ វិភង្គប្បករណំ នាមេតំ ៚

( បាកបិដកលេខ ៨០ )

ខន្ធវិភង្គោ អាយតនវិភង្គោ ធាតុវិភង្គោ សច្ចវិភង្គោ ឥន្ទ្រិយវិភង្គោ បច្ចយាការវិភង្គោ សតិប្បដ្ឋានវិភង្គោ សម្ម-ប្បធានវិភង្គោ ឥទ្ធិបាទវិភង្គោ ពោជ្ឈង្គវិភង្គោ មគ្គវិភង្គោ ឈានវិភង្គោ អប្បមញ្ញាវិភង្គោ សិក្ខាបទវិភង្គោ បដិសម្ភិទា-វិភង្គោ ញាណវិភង្គោ ខុទ្ទកវត្ថុវិភង្គោ ធម្មហទយវិភង្គោតិ អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ ។

### ១.ខន្ធវិភង្គោ

បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។

តត្ថ កតមោ រូបក្ខន្ធោ ។ យំ កិញ្ចិ រូបំ អតីតានា-គតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ រូបក្ខន្ធោ ។

តត្ថ កតមោ វេទនាខន្ធោ ។ យា កាចិ វេទនា អតីតា-នាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វេទនាខន្ធោ ។



តត្ថ កតមោ សញ្ញាខន្ធោ ។ យា កាចិ សញ្ញា អតីតា-នាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ សញ្ញាខន្ធោ ។

តត្ថ កតមោ សង្ខារក្ខន្ធោ ។ យេ កេចិ សង្ខារា អតីតា-នាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ សង្ខារក្ខន្ធោ ។

តត្ថ កតមោ វិញ្ញាណក្ខន្ធោ ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វិញ្ញាណក្ខន្ធោ ។

អយំ ខន្ធវិភង្គោតិ អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម

### ក.រូបក្ខន្ធ

(១) តត្ថ កតមោ រូបក្ខន្ធោ ឯកវិធេន រូបក្ខន្ធោ សព្វំ រូបំ ១.នហេតុ ២.អហេតុកំ ៣.ហេតុវិប្បយុត្តំ ៤.សប្បច្ចយំ ៥.សង្ខតំ ៦.រូបំ ៧.លោកិយំ ៨.សាសវំ ៩.សញ្ញោជនិយំ ១០.គន្ថនិយំ ១១.ឱឃនិយំ ១២.យោគនិយំ ១៣.នីវរណិយំ ១៤.បរាមដ្ឋំ

១៥.ឧបាទានិយំ ១៦.សង្កិលេសិកំ ១៧.អព្យាកតំ ១៨.អនារម្មណំ ១៩.អចេតសិកំ ២០.ចិត្តវិប្បយុត្តំ ២១.នេវវិបាកនវិបាកធម្មធម្មំ ២២.អសង្កិលិដ្ឋសង្កិលេសិកំ ២៣.នសវិតក្កសវិចារំ ២៤.នអវិតក្កវិចារមត្តំ ២៥.អវិតក្កអវិចារំ ២៦.នបីតិសហគតំ ២៧.នសុខសហគតំ ២៨.នឧបេក្ខាសហគតំ ២៩.នេវទស្សនេន ន ភាវនាយ បហាតព្វំ ៣០.នេវទស្សនេន ន ភាវនាយ បហាតព្វហេតុកំ ៣១.នេវាចយគាមិនាបចយគាមិ ៣២.នេវសេក្ខនាសេក្ខំ ៣៣.បរិត្តំ ៣៤.កាមាវចរំ ៣៥.នរូបាវចរំ ៣៦.នអរូបាវចរំ ៣៧.បរិយាបន្នំ ៣៨.នោអបរិយាបន្នំ ៣៩.អនិយតំ ៤០.អនិយ្យានិកំ ៤១.ឧប្បន្នំ ៤២.ឆហិ វិញ្ញាណេហិ វិញ្ញេយ្យំ ៤៣.អនិច្ចំ ៤៤.ជរាភិភូតំ ឯវំ ឯកវិធេន រូបក្ខន្ធោ ។

រូបក្ខន្ធ មានប្រការ ១ ( រូបពួកមួយ ) បានដល់ រូបទាំងពួង ( រូប ២៨ ) ៖

១. **នហេតុ** មិនមែនហេតុ

២. **អហេតុកំ** មិនមានហេតុ

៣. **ហេតុវិប្បយុត្តំ** ប្រាសចាកហេតុ

៤. **សប្បច្ចយំ** ប្រកបដោយបច្ច័យ

៥. **សង្ខតំ** ត្រូវបច្ច័យតាក់តែង

៦. **រូបំ** ជារបស់វិនាស , បែកធ្លាយ



៧. **លោកិយំ** ជាលោកិយៈ

៨. **សាសវំ** ជាអារម្មណ៍នៃអាសវៈ

៩. **សញ្ញោជនិយំ** ជាអារម្មណ៍នៃសញ្ញោជនៈ

១០. **គន្ថនិយំ** ជាអារម្មណ៍នៃគន្ថធម៌

១១. **ឱឃនិយំ** ជាអារម្មណ៍នៃឱឃធម៌

១២. **យោគនិយំ** ជាអារម្មណ៍នៃយោគធម៌

១៣. **នីវរណិយំ** ជាអារម្មណ៍នៃនីវរណធម៌

១៤. **បរាមដ្ឋំ** ជាអារម្មណ៍នៃការស្ទាបអង្អែលដោយទិដ្ឋិ

១៥. **ឧបាទានិយំ** ជាអារម្មណ៍នៃឧបាទាន

១៦. **សង្កិលេសិកំ** គួរដល់សេចក្ដីសៅហ្មង ( ជាអារម្មណ៍នៃកិលេស , អកុសលគ្រប់យ៉ាង )

១៧. **អព្យាកតំ** ជាអព្យាក្រិត

១៨. **អនារម្មណំ** មិនមានអារម្មណ៍ (តែជាអារម្មណ៍)

១៩. **អចេតសិកំ** មិនមានចេតសិក

២០. **ចិត្តវិប្បយុត្តំ** ប្រាសចាកចិត្ត

២១. **នេវវិបាកនវិបាកធម្មធម្មំ** មិនមែនជាវិបាក ទាំងមិននាំឲ្យមានវិបាក

២២. **អសង្កិលិដ្ឋសង្កិលេសិកំ** មិនសៅហ្មង តែគួរដល់សេចក្ដីសៅហ្មង ។

២៣. **នសវិតក្កសវិចារំ** មិនប្រកបដោយវិតក្កៈ វិចារៈ

ឡើយ ( មិនមែនជាចិត្ត ៥៥ ដួង ) ។

២៤. **នអវិតក្កវិចារមត្តំ** មិនមែនមិនមានវិតក្កៈ តែមានវិចារៈឡើយ (មិនមែនទុតិយជ្ឈានចិត្ត ១១ ដួង)។

២៥. **អវិតក្កអវិចារំ** មិនមានវិតក្កៈ មិនមានវិចារៈ ។

២៦. **នបីតិសហគតំ** មិនប្រកបដោយបីតិ ។

២៧. **នសុខសហគតំ** មិនប្រកបដោយសុខ ។

២៨. **នឧបេក្ខាសហគតំ** មិនប្រកបដោយឧបេក្ខា ។

២៩. **នេវទស្សនេន ន ភាវនាយ បហាតព្វំ** មិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា ។

៣០. **នេវទស្សនេន នភាវនាយ បហាតព្វហេតុកំ** មិនមែនមានហេតុដែលត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា ។

៣១. **នេវាចយគាមិនាបចយគាមិ** មិនដល់នូវការសន្សំកពូន ( មិនមែនអកុសលចិត្ត ១២ ដួង លោ-កិយកុសលចិត្ត ១៧ ) ទាំងមិនដល់នូវការមិនសន្សំកពូន ( មិនមែនមគ្គចិត្ត ៤ ) ។

៣២. **នេវសេក្ខនាសេក្ខំ** មិនមែនជាសេក្ខធម៌ ទាំងមិនមែនជាអសេក្ខធម៌ ។

៣៣. **បរិត្តំ** ជាធម៌តូចច្មារ ។

៣៤. **កាមាវចរំ** ជាកាមាវចរៈ ។



**នរូបាវចរំ** មិនមែនជារូបាវចរធម៌ ។

៣៥. **នអរូបាវចរំ** មិនមែនអរូបាវចរធម៌ ។

៣៦. **បរិយាបន្នំ** ជាបរិយាបន្នធម៌ ( បរិយាបន្នធម៌ គឺ ធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ ) ។

៣៧. **នោ អបរិយាបន្នំ** មិនមែនជាអបរិយាបន្នធម៌ ( អបរិយាបន្នធម៌ គឺ ធម៌មិនប្រព្រឹត្តទៅក្នុងភូមិ ៣ បានដល់ លោកុត្តរធម៌ទាំងអស់ ) ។

៣៨. **អនិយតំ** មិនមែនជានិយតធម៌ ( មិនមែនជាអនន្តរិយកម្ម ៥ និងនិយតមិច្ឆាទិដ្ឋិ , មិនមែនជាមគ្គ ៤ ) ។

៣៩. **អនិយ្យានិកំ** មិនមែនជានិយ្យានិកធម៌ ( មិនមែនអរិយមគ្គអដ្ឋ ៨ ) ។

៤០. **ឧប្បន្នំ** ជាធម៌ដែលកើតឡើងហើយ ។

៤១. **ឆហិ វិញ្ញាណេហិ វិញ្ញេយ្យំ** ដែលគួរដឹងដោយវិញ្ញាណ ៦ ។

៤២. **អនិច្ចំ** មិនទៀង ។

៤៣. **ជរាភិភូតំ** ត្រូវជរានាំទៅ ។

“ **ឯវំ ឯកវិធេន រូបក្ខន្ធោ** ”

(២) ទុវិធេន រូបក្ខន្ធោ

១.អត្ថិ រូបំ ឧបាទា អត្ថិ រូបំ នោ ឧបាទា

២.អត្ថិ រូបំ ឧបាទិន្នំ អត្ថិ រូបំ អនុបាទិន្នំ

៣.អត្ថិ រូបំ ឧបាទិន្នុបាទានិយំ អត្ថិ រូបំ អនុបាទិន្នុបាទានិយំ

៤.អត្ថិ រូបំ សនិទស្សនំ  អត្ថិ រូបំ អនិទស្សនំ

៥.អត្ថិ រូបំ សប្បដិឃំ អត្ថិ រូបំ អប្បដិឃំ

៦.អត្ថិ រូបំ ឥន្ទ្រិយំ អត្ថិ រូបំ ន ឥន្ទ្រិយំ

៧.អត្ថិ រូបំ មហាភូតំ  អត្ថិ រូបំ ន មហាភូតំ

៨.អត្ថិ រូបំ វិញ្ញត្តិ អត្ថិ រូបំ ន វិញ្ញត្តិ

៩.អត្ថិ រូបំ ចិត្តសមុដ្ឋានំ អត្ថិ រូបំ ន ចិត្តសមុដ្ឋានំ

១០.អត្ថិ រូបំ ចិត្តសហភុ អត្ថិ រូបំ នចិត្តសហភុ

១១.អត្ថិ រូបំ ចិត្តានុបរិវត្តិ អត្ថិ រូបំ នចិត្តានុបរិវត្តិ

១២.អត្ថិ រូបំ អជ្ឈត្តិកំ អត្ថិ រូបំ ពាហិរំ

១៣.អត្ថិ រូបំ ឱឡារិកំ អត្ថិ រូបំ សុខុមំ

១៤.អត្ថិ រូបំ ទូរេ អត្ថិ  រូបំ សន្តិកេ ។បេ។

១៥.អត្ថិ រូបំ កពឡីការោ អាហារោ អត្ថិ រូបំ នកពឡីការោ អាហារោ  ឯវំ ទុវិធេន រូបក្ខន្ធោ ។

រូបក្ខន្ធ មានប្រការ ២ គឺ ៖

+ គូទី ១ :

អត្ថិ រូបំ ឧបាទា ( រូបជាឧបាទា ក៏មាន ( ឧបាទាយរូប )



អត្ថិ រូបំ នោ ឧបាទា រូបមិនមែនជាឧបាទា ក៏មាន ( ផោដ្ឋព្វាយតនៈ + អាបោធាតុ ) ។

+ គូទី ២ :

អត្ថិ រូបំ ឧបាទិន្នំ រូបជាឧបាទិន្ន ក៏មាន ( កម្មជរូប )

អត្ថិ រូបំ អនុបាទិន្នំ រូបជាឧបាទិន្ន ក៏មាន ( រូបដទៃពីកម្មជរូប ) ( អង្គធម៌ គឺ ក្រៅពីលោកិយវិបាក ៣២ , កម្មជរូបជាអនុបាទិន្នៈ ) ។

+ គូទី ៣ :

អត្ថិ រូបំ ឧបាទិន្នុបាទានីយំ រូបជាឧបាទិន្នុបាទានីយៈ ក៏មាន ( កម្មជរូបទាំងអស់ ដែលជាអារម្មណ៍របស់ឧបាទាន )

អត្ថិ រូបំ អនុបាទិន្នុបាទានីយំ រូបជាអនុបាទិន្នុបាទានីយៈ ក៏មាន ( បានដល់ រូបដែលមិនមែនជាកម្មជរូប និងជាអារម្មណ៍នៃឧបាទាន ) ( អង្គធម៌ លោកិយៈធម៌ទាំងអស់ ) ។

## អធិប្បាយទាក់ទងនឹងមាតិកាធម៌

<u>ទុកមាតិកា</u> :

**១- ឧបាទិន្នា ធម្មា** ពួកធម៌ដែលអាស្រ័យកម្មកិលេសកើតឡើង គឺ លោកិយវិបាកចិត្ត ៣២ ដួង ចេតសិក ៣៥ និងកម្មជរូប ២០ ។

**២- អនុបាទិន្នា ធម្មា** ពួកធម៌ដែលមិនអាស្រ័យកម្មកិលេសគឺកុសលចិត្តទាំងអស់ អកុសលចិត្តទាំងអស់ លោកុ-

ត្តវិបាកចិត្ត កិរិយាចិត្តទាំងអស់ ចេតសិកសម្បយុត្ត និងរូប ៣ សមុដ្ឋាន ( វៀរកម្មជរូប ២០ ) និព្វាន ។

**១-ឧបាទានិយា ធម្មា** ពួកធម៌ជាអារម្មណ៍នៃឧបាទាន = លោកិយា ធម្មា ។

**២-អនុបាទានិយា ធម្មា** ពួកធម៌មិនមែនជាអារម្មណ៍នៃឧបាទាន = លោកុត្តរា ធម្មា ។

**<u>តិកមាតិកា</u> :**

**១-ឧបាទិន្នុបាទានិយា ធម្មា** ពួកធម៌អាស្រ័យកម្មកិលេសកើតឡើង ទាំងជាអារម្មណ៍នៃឧបាទាន គឺ លោកិយវិបាក , ចិត្តចេតសិក និងកម្មជរូប ។

**២-អនុបាទិន្នុបាទានិយា ធម្មា** ពួកធម៌មិនអាស្រ័យកម្មកិលេសកើតឡើង តែជាអារម្មណ៍នៃឧបាទាន បានដល់ លោកិយកុសលចិត្ត ១៧ អកុសលចិត្ត ១២ កិរិយាចិត្ត ២០ ចេតសិកសម្បយុត្ត និងរូបដែលមិនមែនជាកម្មជរូប ។

**៣-អនុបាទិន្នានុបាទានិយា ធម្មា** ពួកធម៌មិនអាស្រ័យកម្មកិលេស ទាំងមិនជាអារម្មណ៍នៃឧបាទាន បានដល់ លោកុត្តរធម៌ ( មគ្គ ៤ ផល ៤ និព្វាន ) ។

**+ គូទី ៤ :**

**អត្ថិ រូបំ សនិទស្សនំ** រូបដែលគួរដល់ការឃើញ ក៏មាន បានដល់ រូបារម្មណ៍ ។



**អត្ថិ រូបំ អនិទស្សនំ** រូបមិនគួរដល់ការឃើញ ក៏មាន បានដល់ រូប ២៧ ( វៀរ រូបារម្មណ៍ ) ។

**+ គូទី ៥ :**

**អត្ថិ រូបំ សប្បដិឃំ** រូបដែលគួរដល់ការប៉ះខ្ទប់ ក៏មាន បានដល់ ឱឡារិករូប ១២ ( សង្គ្រោះក្នុងអាយតនៈ ១០ គឺ បសាទរូប ៥ , គោចររូប ៧ ជាអាយតនៈ ៥ ) ។

**អត្ថិ រូបំ អប្បដិឃំ** រូបមិនគួរដល់ការប៉ះខ្ទប់ ក៏មាន បានដល់ សុខុមរូប ១៦ ។

**+ គូទី ៦ :**

**អត្ថិ រូបំ ឥន្ទ្រិយំ** រូបដែលជាធំ ក្នុងកិច្ចរបស់ខ្លួន ក៏មាន បានដល់ ឥន្ទ្រិយរូប ៨ គឺ បសាទរូប ៥ ជីវិតរូប ១ ភាវរូប ២ ។

**អត្ថិ រូបំ នឥន្ទ្រិយំ** រូបដែលមិនមែនជាធំ ក្នុងកិច្ចរបស់ខ្លួន ក៏មាន បានដល់ អនិន្ទ្រិយរូប ២០ ។

**+ គូទី ៧ :**

**អត្ថិ រូបំ មហាភូតំ** ( មហាភូតរូប ៤ ) ។

**អត្ថិ រូបំ ន មហាភូតំ** ( ឧបាទាយរូបទាំងអស់ ) ។

**+ គូទី ៨ :**

**អត្ថិ រូបំ វិញ្ញត្តិ** ( វិញ្ញត្តិរូប ២ ) ។

**អត្ថិ រូបំ ន វិញ្ញត្តិ** ( រូបដទៃអំពីវិញ្ញត្តិរូប ) ។

**+ គូទី ៩ :**

**អត្ថិ រូបំ ចិត្តសមុដ្ឋានំ** រូបមានចិត្តជាសមុដ្ឋាន ក៏មាន ។

**អត្ថិ រូបំ ន ចិត្តសមុដ្ឋានំ** រូបដែលមិនមែនមានជាចិត្តសមុដ្ឋាន ក៏មាន ។

**+ គូទី ១០ :**

**អត្ថិ រូបំ ចិត្តសហភុ** រូបកើតព្រមជាមួយចិត្ត ក៏មាន បានដល់ វិញ្ញត្តិរូប ២ ។

**អត្ថិ រូបំ នចិត្តសហភុ** រូបដទៃក្រៅអំពីវិញ្ញត្តិរូប ២ ។

**+ គូទី ១១ :**

**អត្ថិ រូបំ ចិត្តានុបរិវត្តិ** រូបជាចិត្តានុបរិវត្តិ ក៏មាន ។

**អត្ថិ រូបំ នចិត្តាបរិវត្តិ** រូបមិនមែនជាចិត្តានុបរិវត្តិ ក៏មាន ។

**+ គូទី ១២ :**

**អត្ថិ រូបំ អជ្ឈត្តិកំ** រូបជាខាងក្នុង ក៏មាន ។

**អត្ថិ រូបំ ពាហិរំ** រូបជាខាងក្រៅ ក៏មាន ។

**+ គូទី ១៣ :**

**អត្ថិ រូបំ ឱឡារិកំ** រូបគ្រោតគ្រាត ក៏មាន ។

**អត្ថិ រូបំ សុខុមំ** រូបល្អិត ក៏មាន ។

**+ គូទី ១៤ :**

**អត្ថិ រូបំ ទូរេ** រូបតាំងនៅក្នុងទីឆ្ងាយ ក៏មាន ។

**អត្ថិ រូបំ សន្តិកេ** រូបតាំងនៅក្នុងទីជិត ក៏មាន ។ បេ ។



**+ គូទី ១៥ :**

**អត្ថិ រូបំ កពឡីការោ អាហារោ** រូបជាកពឡិង្ការាហារ ក៏មាន ។

**អត្ថិ រូបំ នកពឡីការោ អាហារោ** រូបមិនមែនជាកពឡិង្ការាហារ ក៏មាន ។

( រូបក្ខន្ធ មានប្រការ ២ យ៉ាងនេះឯង )

## តិវិធេន រូបក្ខន្ធោ

រូបក្ខន្ធ មានប្រការ ៣ គឺ ៖

**- យន្តំ រូបំ អជ្ឈត្តិកំ តំ ឧបាទា** រូបណាខាងក្នុង រូបនោះជាឧបាទា ( បសាទរូប ៥ , ដែលពោលថាជារូបខាងក្នុង ព្រោះត្រូវទទួលការប៉ះខ្ទប់នូវអារម្មណ៍ ) ។

**- យន្តំ រូបំ ពាហិរំ តំ អត្ថិ ឧបាទា** រូបណាខាងក្រៅ រូបនោះជាឧបាទា ក៏មាន ( ឧបាទាយរូប ១៩ ) ។

**- យន្តំ រូបំ ពាហិរំ តំ អត្ថិ អនុបាទា** រូបណាខាងក្រៅ រូបនេះមិនមែនជាឧបាទា ក៏មាន ( មហាភូតរូប ៤ ) ។

## ជរាសូត្រ

( ចាកបិដកលេខ ៥៤ )

**គាថាទី ១ :**

**អប្បំ វត ជីវិតំ ឥទំ ឱរំ វស្សសតាបិ មិយ្យតិ**
**សចេបិ អតិច្ច ជីវតិ អថខោ សោ ជរសាបិ មិយ្យតិ ។**

ជីវិតនេះមានប្រមាណតិចហ្ន៎ សត្វតែងស្លាប់ថយអំពី ១០០ ឆ្នាំ ប្រសិនបើរស់ហួសពី ១០០ ឆ្នាំ សត្វនោះ នឹងស្លាប់ដោយជរាជាប្រាកដ ។

**គាថាទី ២ :**

**សោចន្តិ ជនា មមាយិតេ ន ហិ សន្តិ និច្ចា បរិគ្គហា**
**វិនាភាវសន្តមេវិទំ ឥតិ ទិស្វា នាគារមាវសេ ។**

ជនទាំងឡាយតែងសោក ព្រោះវត្ថុដែលប្រកាន់ថា របស់យើង សេចក្តីប្រកាន់ជារបស់ទៀងទាត់មិនមានឡើយ ជីវិតនេះមានការព្រាត់ប្រាសចាករបស់ដែលមានជាធម្មតា អ្នកមានប្រាជ្ញាលុះឃើញដូច្នេះហើយ រមែងមិននៅគ្រប់គ្រងផ្ទះឡើយ ។

**គាថាទី ៣ :**

**មរណេនបិ តំ បហេយ្យតិ យំ បុរិសោ មមយិទន្តិ មញ្ញតិ**



**ឯតម្បិ វិទិត្វា បណ្ឌិតោ ន មមត្តាយ នមេថ មាមកោ ។**

បុរសសម្គាល់របស់ណាថា នេះជារបស់អញ រមែងលះរបស់នោះដោយមរណៈ ឯអ្នកប្រាជ្ញរាប់អានព្រះរតនត្រ័យ ជ្រាបច្បាស់នូវទោសនោះហើយ មិនបង្អោនចិត្តទៅដើម្បីសេចក្តីប្រកាន់ថារបស់យើងឡើយ ។

**គាថាទី ៤ :**

**សុបិនេន យថាបិ សង្គតំ បដិពុទ្ធោ បុរិសោ ន បស្សតិ**
**ឯវម្បិ បិយាយិតំ ជនំ បេតំ កាលកតំ ន បស្សតិ ។**

បុរសអ្នកភ្ញាក់ ( ពីដេក ) រមែងមិនឃើញរូបារម្មណ៍ជាដើម ដែលមកជួបប្រទះដោយយល់សប្តិ យ៉ាងណាមិញ បុគ្គលមិនឃើញជនជាទីស្រឡាញ់ ដែលធ្វើកាលកិរិយាទៅកាន់លោកខាងមុខ ក៏យ៉ាងនោះដែរ ។

**គាថាទី ៥ :**

**ទិដ្ឋាបិ សុតាបិ តេ ជនា យេសំ នាមមិទំ បវុច្ចតិ**
**នាមមេវាវសិស្សតិ អក្ខេយ្យំ បេតស្ស ជន្តុនោ ។**

ជនទាំងនោះ ដែលគេឃើញហើយ ឮហើយ គេតែងហៅឈ្មោះ កាលលះលោកនេះទៅ នៅសល់តែឈ្មោះសម្រាប់ហៅប៉ុណ្ណោះ ។

**គាថាទី ៦ :**

**សោកបរិទេវមច្ឆរំ ន ជហន្តិ គិទ្ធា មមាយិតេ**

**តស្មា មុនយោ បរិគ្គហំ ហិត្វា អចរឹសុ ខេមទស្សិនោ ។**

ពួកសត្វមានសេចក្តីលោភ តែងមិនលះបង់នូវសេចក្តីសោកខ្សឹកខ្សួល និងសេចក្តីកំណាញ់ក្នុងវត្ថុដែលជាទីរាប់អានបានឡើយ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយដែលឃើញព្រះនិព្វានថាជាទីក្សេមហើយ រមែងលះបង់សេចក្តីប្រកាន់បាន ។

**គាថាទី ៧ :**

**បជិលីនចរស្ស ភិក្ខុនោ ភជមានស្ស វិវិត្តមាសនំ**
**សាមគ្គិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ទស្សយេ ។**

ភិក្ខុណា មិនសម្តែងខ្លួនក្នុងភព ( ថ្មីទៀត ) អ្នកប្រាជ្ញទាំងឡាយហៅអំពើនោះ របស់ភិក្ខុនោះ អ្នកប្រព្រឹត្តរួញរា អ្នកភពប្រសព្វអាសនៈស្ងាត់ ថាជាសភាពសមរម្យហើយ ។

## អដ្ឋកថា ជរាសូត្រ

**( ស្រង់ចំនុចខ្លះៗ ចាកអដ្ឋកថាលេខ ៤៧ ទំព័រ ៧៣៤ )**

ជរាសូត្រ មានពាក្យផ្តើមថា **អប្បំ វត ជីវិតំ** ជីវិតមានប្រមាណតិចហ្ន៎ ដូច្នេះ ។

ព្រះសូត្រនេះ មានការកើតឡើងដូចម្តេច ?

សម័យមួយ ព្រះមានព្រះភាគ ទ្រង់ចាំវស្សានៅក្រុងសាវត្ថី ទ្រង់ពិចារណាដល់ការប្រព្រឹត្តរបស់ព្រះពុទ្ធទាំងឡាយក្នុងការស្តេចចារិកទៅកាន់ជនបទ មានជាអាទិ៍ គឺ ឲ្យដល់ការមិនមានរោគ បញ្ញត្តិសិក្ខាបទដែលមិនទាន់បានបញ្ញត្តិទុក ទូន្មាន



វេនេយ្យសត្វ និទានជាតកជាដើម ដែលជាដើមហេតុឲ្យកើតរឿងនោះ ៗ ទើបស្តេចចារិកទៅកាន់ជនបទ ។ល។

មាននិទានថា មានព្រាហ្មណ៍-ព្រាហ្មណីមហាសាល ដែលនៅក្នុងដែនសាកេត ចេញអំពីដែនបានឃើញព្រះសាស្តា ក៏សម្គាល់ថាដូចជាកូនរបស់ខ្លួនបង្កើត រហូតជនទាំងឡាយនាំគ្នាពោលដល់ព្រាហ្មណ-ព្រាហ្មណីថា ជាពុទ្ធបិតា ពុទ្ធមាតា ។ តែត្រកូលនោះ មិនមែនឈ្មោះដូច្នោះឡើយ ។ ព្រះមានព្រះភាគត្រាស់នឹងសំណួររបស់ព្រះអានន្ទថា នាងព្រាហ្មណី និងព្រាហ្មណ៍ធ្លាប់ជាមាតា.បិតារបស់តថាគតជាលំដាប់មក ៥០០ ជាតិហើយ ជាឪពុកធំ ជាម្តាយធំ របស់តថាគតមក ៥០០ ជាតិ ជាឪពុកមាម្តាយមីងមក ៥០០ ជាតិ ព្រាហ្មណ៍ និងព្រាហ្មណីនោះ ពោលដោយសេចក្តីស្រឡាញ់ក្នុងជាតិមុននោះឯង និងបានត្រាស់គាថានេះថា ៖

**សេចក្តីស្រឡាញ់ រមែងកើតព្រោះ**
**ធ្លាប់នៅរួមគ្នាមកអំពីមុន ឬព្រោះទំនាក់**
**ទំនងគ្នាក្នុងបច្ចុប្បន្ន ដូចជាផ្កាឈូកកើត**
**ក្នុងទឹក ដូច្នោះ ។**

ព្រះមានព្រះភាគ ទ្រង់ពិចារណាមើលបរិស័ទនោះ កាលនឹងទ្រង់សម្តែងធម៌សមគួរដល់ខណៈនោះ ទើបបានត្រាស់ព្រះ-សូត្រនេះ ។

ក្នុងបទទាំងនោះ បទថា **អប្បំ វត ជីវិតំ ឥទំ** ជីវិតនេះមានប្រមាណតិចហ្ន៎ ដូចបានពោលហើយក្នុងសល្លសូត្រថា ជីវិតរបស់មនុស្សទាំងឡាយមានតិចតួចណាស់ ព្រោះតាំងនៅត្រឹមតែមួយរំពេច ព្រោះបានរស់នៅត្រឹមតែមួយភ្លែត ដូច្នេះ ។ បទថា **ឱរំ វស្សតាបិ មិយ្យតិ** សត្វស្លាប់សូម្បីក្នុងចំណែក ១០០ ឆ្នាំ គឺ ស្លាប់សូម្បីក្នុងកាលជាកលលៈ ( រូបដែលកើតជាគ្រាដំបូង ក្នុងខណៈតាំងគភ៌ ) តិចជាង ១០០ ឆ្នាំ ។ បទថា **អតិច្ច** ច្រើនជាង គឺ លើស ១០០ ឆ្នាំ ។ បទថា **ជរសាបិ មិយ្យតិ** គឺ សត្វនោះរមែងស្លាប់ព្រោះជរា ។

បទថា **មមាយិតេ** គឺ ព្រោះវត្ថុដែលខ្លួនប្រកាន់ថាជារបស់យើង ។ បទថា **វិនាភាវសន្តមេវិទំ** គឺ វត្ថុនេះមានការព្រាត់ប្រាសចាកគ្នាហើយ លោកអធិប្បាយថា នឹងមិនមានការព្រាត់ប្រាសចាកគ្នាមិនបាន ។ បទថា **មាមកោ** អ្នករាប់អានព្រះពុទ្ធថា ជារបស់យើង គឺ រាប់អានថា ឧបាសក ឬភិក្ខុរបស់យើង ឬរាប់អានព្រះពុទ្ធជាដើមថាជារបស់យើង ។ បទថា **សង្គតំ** អារម្មណ៍ដែលប្រសព្វ គឺ អារម្មណ៍ដែលមកដល់ ឬធ្លាប់ឃើញ ។ បទថា **បិយាយិតំ** បុគ្គលដែលខ្លួនស្រឡាញ់ គឺ បុគ្គលដែលខ្លួនធ្វើឲ្យជាទីស្រឡាញ់ ។ បទថា **នាមមេវាវសិស្សតិ អក្ខេយ្យំ** ឈ្មោះប៉ុណ្ណោះដែលគួរពោលដល់ គឺ ធម្មជាតិមានរូបជាដើមទាំងអស់បែកធ្លាយទៅ ចំណែកឈ្មោះរមែង



តាំងនៅ ដើម្បីហៅគ្នាយ៉ាងនេះថា **ពុទ្ធរក្ខិតោ ធម្មរក្ខិតោ** ។ បទថា **មុនយោ** មុនីទាំងឡាយ បានដល់ ព្រះមុនីដែលជាខីណាស្រព ។ បទថា **ខេមទស្សិនោ** បានដល់ អ្នកឃើញនិព្វាន ។

ព្រះមានព្រះភាគត្រាស់គាថាទី ៧ ដើម្បីទ្រង់សម្តែងដល់ការបដិបត្តិដ៏សមគួរក្នុងលោក ដែលត្រូវសេចក្តីស្លាប់កម្ចាត់យ៉ាងនេះ ។

ក្នុងបទទាំងនោះ បទថា **បដិលីនចរស្ស** របស់ភិក្ខុដែលប្រព្រឹត្តគេចចេញហើយ គឺ របស់ភិក្ខុដែលប្រព្រឹត្តធ្វើចិត្តគេចចេញពីទីនោះ ៗ ។ បទថា **ភិក្ខុនោ** បានដល់ កល្យាណបុថុជ្ជន ឬព្រះសេក្ខៈ ។ បទថា **សាមគ្គិយមាហុ តស្ស តំ យោ អត្តានំ ភវនេ ន ទស្សយេ** សេចក្តីថា បណ្ឌិតទាំងឡាយពោលអ្នកដែលបដិបត្តិយ៉ាងនេះ មិនសម្តែងខ្លួនក្នុងភពដែលផ្សេងដោយនរកជាដើម ថាជាការសមគួរ ។ អធិប្បាយថា ក្រៃលែងជាងនោះ បណ្ឌិតនោះ គប្បីរួចផុតចាកសេចក្តីស្លាប់ ។

ពេលនេះ ព្រះមានព្រះភាគ ត្រាស់ដល់ព្រះខីណាស្រពយ៉ាងនេះថា អ្នកដែលមិនសម្តែងខ្លួនក្នុងភព ដូច្នេះ ទើបត្រាស់គាថា ៣ គាថា តអំពីនេះដើម្បីពណ៌នាគុណរបស់ព្រះខីណាស្រពនោះ ។

ក្នុងបទទាំងនោះ បទថា **សព្វត្ថ** ក្នុងអាយតនៈទាំងពួង គឺ ក្នុងអាយតនៈ ១២ ។ ក៏ក្នុងបទនេះថា **យទិទំ ទិដ្ឋំ សុតំ**

**មុតេសុ វា** គប្បីជ្រាបការក្ខាប់សេចក្តីយ៉ាងនេះថា មុនីរមែងមិនជាប់នៅក្នុងរូបដែលបានឃើញ ក្នុងសំឡេងដែលបានឮ ឬក្នុងអារម្មណ៍ដែលបានប៉ះពាល់ យ៉ាងនេះ ។ បទថា **ធោនោ ន ហិ តេន មញ្ញតិ យទិទំ ទិដ្ឋំ សុតំ មុតេសុ វា** គប្បីជ្រាបការក្ខាប់សេចក្តីយ៉ាងនេះដូចគ្នាថា អ្នកមានបញ្ញា រមែងមិនសម្គាល់ក្នុងរូបដែលបានឃើញ សំឡេងដែលបានស្តាប់ ឬរមែងមិនសម្គាល់ក្នុងអារម្មណ៍ដែលពាល់ត្រូវ ។ បទថា **ន ហិ សោ រជ្ជតិ នោ វិរជ្ជតិ** អ្នកមានបញ្ញានោះ រមែងមិនត្រេកអរ រមែងមិនទាស់ចិត្ត សេចក្តីថា អ្នកមានបញ្ញារមែងមិនត្រេកអរ ដូចបុថុជ្ជនដែលជាពាល រមែងមិនទាស់ចិត្ត ដូចកល្យាណបុថុជ្ជន និងព្រះសេក្ខៈ រមែងបានឈ្មោះថា ជាអ្នកមិនត្រេកអរ មិនទាស់ចិត្ត ព្រោះអស់រាគៈហើយនោះឯង ។ បទដ៏សេសក្នុងទីទាំងពួងជាក់ច្បាស់ល្អហើយ ។

*ក្នុងវេលាចប់ធម្មទេសនា សត្វ ៨៤.០០០ បានសម្រេចហើយ*

*ចប់អដ្ឋកថាជរាសូត្រទី ៦ នៃអដ្ឋកថាខុទ្ទកនិកាយ*

*អដ្ឋកវគ្គ*

*ឈ្មោះ បរមត្ថជោតិកា*